# ធនធានមគ្គុទ្ទេសក៍សម្រាប់ជនអន្តោប្រវេសន៍
## កម្មវិធី និងសេវា ដែលផ្តល់ជូនដោយ

Alameda County
Social Services
Agency

## និងដៃគូសហគមន៍

**ទីតាំងការិយាល័យ SSA**

**ម៉ោងធ្វើការ**
ថ្ងៃចន្ទ ដល់សុក្រ
ម៉ោង 8:30 ព្រឹក - 5:00 ល្ងាច

**North County Self-Sufficiency Center**
2000 San Pablo Ave.
Oakland, CA 94612

**Eastmont Self-Sufficiency Center**
6955 Foothill Blvd., Suite 100
Oakland, CA 94605

**Enterprise Self-Sufficiency Center**
8477 Enterprise Way
Oakland, CA 94621

**Eden Area Multi-Service Center**
24100 Amador St.
Hayward, CA 94544

**Fremont Office**
39155 Liberty St., Suite C330
Fremont, CA 94536

**Livermore Office**
2481 Constitution Drive, Suite B
Livermore, CA 94551

**គេហទំព័រ:**
www.alamedasocialservices.org

**មជ្ឈមណ្ឌលបម្រើទូរស័ព្ទអតិថិជន:**
(510) 263-2420 or (888) 999-4772

**211 Alameda County**
ហៅទូរស័ព្ទលេខ 2-1-1 សម្រាប់ព័ត៌មានសម្ងាត់ និងឥតគិតថ្លៃ និងការបញ្ជូនទៅសេវាលំនៅដ្ឋាន សេវាថែទាំសុខភាព និងសេវាសង្គមកិច្ច។ មានជូន 24 ម៉ោងរាល់ថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

**មាតិកា:**


| | |
|---|---|
| ជំនួយម្ហូបអាហារ | 2 |
| ជំនួយវេជ្ជសាស្ត្រ | 2 |
| ជំនួយសាច់ប្រាក់ | 2 |
| ជំនួយថ្លៃឈ្នួលក្នុងគ្រាអាសន្ន | 4 |
| សេវាការងារ | |
| សេវាមនុស្សពេញវ័យ & ចាស់ជរា | 4 |
| សេវាកុមារ & គ្រួសារ | 6 |
| ការរៀបចំបង់ពន្ធដោយមិន | 6 |
| ចំណាយ | 8 |
| ធនធានសហគមន៍ | 8 |


## សំខាន់!

- វិធានស្តីពីអត្ថប្រយោជន៍សាធារណៈ: ពុំទាន់មានការផ្លាស់ប្តូរទេ។
- ព័ត៌មាន ដែលបានផ្តល់ឲ្យ SSA គឺជាការសម្ងាត់ និងត្រូវបានយកប្រើប្រាស់ ដើម្បីកំណត់ពីសិទ្ធិទទួលបានអត្ថប្រយោជន៍តែប៉ុណ្ណោះ។
- បុគ្គល និងគ្រួសារអាចបន្តដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ និងសេវាតាមសេចក្តីត្រូវការ។
- កុំបង់ប្រាក់ឲ្យជនផ្សេង ដើម្បីឲ្យគេជួយអ្នកបំពេញពាក្យសុំសម្រាប់កម្មវិធី និងសេវា SSA ។ យើងនៅទីនេះដើម្បីជួយអ្នកដាក់ពាក្យស្នើសុំ!

## ជំនួយម្ហូបអាហារ

### CalFresh (ពីមុន ហៅថា Food Stamps) - ជំនួយអាហារបំប៉ន

CalFresh ផ្តល់ជំនួយអាហារបំប៉នប្រចាំខែដល់បុគ្គល និង គ្រួសារចំណូលទាប ដើម្បីទិញម្ហូបអាហារជួយឲ្យមានសុខភាពល្អ។ អត្ថប្រយោជន៍ CalFresh ត្រូវទទួលបាន តាមរយៈការប្រើ ប័ណ្ណ EBT (ផ្ទេរអត្ថប្រយោជន៍អេឡិចត្រូនិក)។

សិទ្ធិទទួលបាន៖ ពលរដ្ឋអាមេរិក និងអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់** នៅទីតាំងការិយាល័យ SSA ណាមួយ
- **តាមទូរស័ព្ទ៖** 1-888-999-4772 ឬ 510-263-2420
- **អនឡាញ៖** mybenefitscalwin.org

**ខ្សែទូរស័ព្ទផ្តល់ជំនួយ សម្រាប់ប័ណ្ណផ្ទេរអត្ថប្រយោជន៍អេឡិត្រូនិក (Electronic Benefits Transfer (EBT) Helpline)**

(ប្រសិនបើជួយបញ្ហាផ្សេងៗ ទាក់ទងនឹងប័ណ្ណរបស់អ្នក)៖1-877-328-9677

**សម្រាប់ព័ត៍មានបន្ថែម៖**

**វេបសាយ៖** www.alamedasocialservices.org/public/services/food_assistance/index.cfm

### កម្មវិធីជំនួយម្ហូបអាហាររដ្ឋ California (CFAP) - ជំនួយអាហារបំប៉ន

ជំនួយពីមូលនិធិរដ្ឋសម្រាប់មនុស្សមិនមែនជាពលរដ្ឋ ដែលមានលក្ខណ:សម្បត្តិ និងដែលគ្មានលក្ខណ:សម្បត្តិទទួលបានអត្ថប្រយោជន៍របស់រដ្ឋសហព័ន្ធ ដើម្បីទិញម្ហូបអាហារបំប៉ន។

សិទ្ធិទទួលបាន៖ ជនអន្តោប្រវេសន៍ភាគច្រើន – អ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់** នៅទីតាំងការិយាល័យ SSA ណាមួយ
- **តាមទូរស័ព្ទ៖** 1-888-999-4772 ឬ 510-263-2420
- **អនឡាញ៖** mybenefitscalwin.org

**សម្រាប់ព័ត៍មានបន្ថែម៖**

**វេបសាយ៖** https://california-foodstamps.org/calfresh-for-non-citizens.html

## ជំនួយវេជ្ជសាស្ត្រ

### Medi-Cal – ការទទួលបានសេវាថែទាំសុខភាព

ការធានារ៉ាប់រងសុខភាពឥតគិតថ្លៃ ឬចំណាយទាប សម្រាប់ កុមារ គ្រួសារ ចាស់ជរា និងជនពិការ ដែលចំណូល និង ធនធានមានដែនកំណត់។

សិទ្ធិទទួលបាន៖ ពលរដ្ឋអាមេរិក និងអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់** នៅទីតាំងការិយាល័យ SSA ណាមួយ
- **តាមប្រៃសណីយ៍៖** ទូរស័ព្ទមក 510-777-2300 ឬ 1-800-698-1118 (ឥតគិតថ្លៃទូរស័ព្ទ) ដើម្បីស្នើសុំ ពាក្យសុំ Medi-Cal ផ្ញើតាមប្រៃសណីយ៍ និង កូនសៀវភៅណែនាំ។
- **អនឡាញ៖** mybenefitscalwin.org ឬតាមរយ: Covered California នៅ CoveredCa.com

**សម្រាប់ព័ត៍មានបន្ថែម៖**

**វេបសាយ៖** www.alamedasocialservices.org/public/services/medical_and_health/families_with_children.cfm

## ជំនួយសាច់ប្រាក់

### Refugee Cash Assistance (RCA)

ផ្តល់ជំនួយសាច់ប្រាក់ និងវេជ្ជសាស្ត្រ (កម្មវិធីជំនួយវេជ្ជសាស្ត្រជនភៀសខ្លួន) ឲ្យជនភៀសខ្លួនមិនមែនជាពលរដ្ឋ ដែលគ្មានកូន ដែលគ្មានសិទ្ធិទទួលជំនួយសាច់ប្រាក់ដទៃទៀត។ បុគ្គលមានសិទ្ធិ អាចទទួលបានជំនួយ RCA, Medi-Cal, និង CalFresh ក្នុងអំឡុងប្រាំបីខែដំបូង នៅសហរដ្ឋអាមេរិក។ អតិថិជន RCAត្រូវចុះឈ្មោះនិងចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសេវាការងារ មុនពេលគេអាចអនុម័តផ្តល់ជំនួយឲ្យ។

សិទ្ធិទទួលបាន៖ ជនភៀសខ្លួន មិនមែនជាពលរដ្ឋ ដែលពុំមានសិទ្ធិទទួលបានជំនួយ CalWORKs។ សិទ្ធិទទួលបាន ផ្អែកលើស្ថានការណ៍នីមួយៗ។

**របៀបស្នើសុំ៖**

- បុគ្គល ចង់សុំ RCA ត្រូវដាក់ពាក្យសុំ CalWORKs **ដោយផ្ទាល់** នៅទីតាំងការិយាល័យ SSA ណាមួយ ឬ **អនឡាញ** នៅ mybenefitscalwin.org

**សម្រាប់ព័ត៍មានបន្ថែម៖**

**វេបសាយ៖** www.alamedasocialservices.org/public/services/financial_assistance/refugee_cash_assistance.cfm

## Cash Assistance Program for Immigrants (CAPI)

CAPI ផ្តល់ជំនួយដល់បុគ្គលស្របច្បាប់ មិនមែនជាពលរដ្ឋ ដែលខ្វះខាតហិរញ្ញវត្ថុ និងគ្មានសិទ្ធិទទួលបានចំណូលសន្តិសុខបន្ថែម (Supplemental Security Income (SSI)) របស់រដ្ឋសហព័ន្ធ ដោយសារឋានៈអន្តោប្រវេសន៍។ សិទ្ធិទទួលបាន ផ្អែកលើស្ថានការណ៍នីមួយៗ។

សិទ្ធិទទួលបាន៖
ជនអន្តោប្រវេសន៍ពិការ ឬពិការភ្នែកគ្រប់វ័យ ឬចាស់ជរាអាយុ 65 ឆ្នាំ និងលើសនេះ ដែល

- គ្មានសិទ្ធិទទួលបានចំណូលសន្តិសុខបន្ថែម/ប្រាក់បន្ថែមពីរដ្ឋ (Supplemental Security Income/State Supplementary Payment (SSI/SSP)) ដោយសារឋានៈអន្តោប្រវេសន៍ និង
- គ្មានចំណូលសោះ ទ្រព្យសរុបតិចជាង $2,000 បើនៅលីវ និងមិនលើសពី $3,000 បើរៀបការរួច។

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់** នៅទីតាំងការិយាល័យ SSA ណាមួយ

**សម្រាប់ព័ត៌មានបន្ថែម៖**

**ព័ត៌មានដែលបានថតទុក៖** ទូរស័ព្ទទៅ 1-800-648-0954 ឬ 510-268-2332

**វេបសាយ៖** www.alamedasocialservices.org/public/services/financial_assistance/cash_assistance_program_for_immigrants.cfm

## CalWORKs (California Work Opportunities and Responsibilities to Kids)

ផ្តល់ជំនួយសាច់ប្រាក់ដែលមានរយៈពេលកំណត់ សេវាគាំពារផ្នែកការងារ និង/ឬសេវាសម្រាប់ជនអនាថា ផ្អែកលើចំណូលបុគ្គល និងគ្រួសារ ដល់គ្រួសារដែលមានសិទ្ធិ ដែលមានកូននៅផ្ទះ។

បើគ្មានការលើកលែងទេ អ្នកទទួលជំនួយ CalWORKs ត្រូវចូលរួមក្នុងសកម្មភាព Welfare- to-Work (WtW) ឬធ្វើការ 20 ម៉ោងក្នុងមួយសប្តាហ៍ ចំពោះគ្រួសារមានតែឪពុក/ម្តាយ ដែលមានកូនម្នាក់អាយុក្រោម 6 ឆ្នាំ; 30 ម៉ោងក្នុងមួយសប្តាហ៍ចំពោះគ្រួសារមានតែឪពុក/ម្តាយ ដែលគ្មានកូនអាយុក្រោម 6 ឆ្នាំ និង 35 ម៉ោងក្នុងមួយសប្តាហ៍ ចំពោះគ្រួសារមានទាំងឪពុកនិងម្តាយ។

– ជំនួយសាច់ប្រាក់ ត –

សិទ្ធិទទួលបាន៖

អ្នកស្នាក់នៅក្នុងរដ្ឋ California ដែល

- ពលរដ្ឋអាមេរិក
- មិនមានជាពលរដ្ឋអាមេរិក តែមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់
- មិនមែនជាពលរដ្ឋ តែមានលក្ខណៈសម្បត្តិ ឬ
- ជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងបទឧក្រិដ្ឋធ្ងន់ធ្ងរផ្សេងទៀត។

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់** នៅទីតាំងការិយាល័យ SSA ណាមួយ
- **អនឡាញ៖** mybenefitscalwin.org

**សម្រាប់ព័ត៌មានបន្ថែម៖**

**វេបសាយ៖** www.alamedasocialservices.org/public/services/financial_assistance/calWorks_eligibility.cfm

## ជំនួយទូទៅ

កម្មវិធីកម្ចីដែលឧបត្ថម្ភដោយខោនធី ផ្តល់ជំនួយសាច់ប្រាក់ដល់មនុស្សពេញវ័យនៅលីវ ប្តីប្រពន្ធរៀបការដែលគ្មានកូនក្នុងបន្ទុក និងអនីតិជនដែលរួចពីអាណាព្យាបាលភាព។ អ្នកដាក់ពាក្យសុំ និងអ្នកទទួលបានជំនួយទូទៅ ក៏អាចមានសិទ្ធិទទួលបានជំនួយបន្ថែមផ្នែកការងារ ម្ហូបអាហារ និងវេជ្ជសាស្ត្រផងដែរ។

សិទ្ធិទទួលបាន៖

- ពលរដ្ឋអាមេរិក
- អ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់
- បុគ្គលមិនមែនជាពលរដ្ឋ ដែលទទួលបានការឧបត្ថម្ភ
- បុគ្គលមិនមែនជាពលរដ្ឋដទៃទៀត ដែលអាចមានសិទ្ធិផ្អែកលើស្ថានការណ៍នីមួយៗ។

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់** នៅទីតាំងការិយាល័យ SSA ណាមួយ

**សម្រាប់ព័ត៌មានបន្ថែម៖**

**វេបសាយ៖** www.alamedasocialservices.org/public/services/financial_assistance/general_assistance.cfm

**ជំនួយថ្លៃឈ្នួលក្នុងគ្រាអាសន្ន**

## Season of Sharing

Season of Sharing ផ្តល់ជំនួយម្តង ផ្អែកលើវិបត្តិចំពោះសេចក្តីត្រូវការសំខាន់ក្នុងគ្រួសារ និងផ្អែកលំនៅដ្ឋានអចិន្ត្រៃយ៍ដល់អ្នកស្នាក់នៅក្នុងខោនធី Alameda។ កម្មវិធីនេះចង់ជួយគ្រួសារដែលមានសិទ្ធិ មានស្ថេរភាពឡើងវិញ បន្ទាប់ពីជួបស្ថានការណ៍អាសន្ន ដែលមិនអាចប្រមើលឃើញ ដែលហួសពីការគ្រប់គ្រងរបស់ខ្លួន។

<u>សិទ្ធិទទួលបាន៖</u>

ដើម្បីទទួលបានការពិចារណា អ្នកស្នើសុំត្រូវតែជាអ្នកស្នាក់នៅបច្ចុប្បន្នក្នុងខោនធី Alameda យ៉ាងតិច 6 ខែបន្តបន្ទាប់ ឬយូរជាងនេះ និងបំពេញនូវលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោម៖

- ចាស់ជរាអាយុ 55 ឆ្នាំ និងច្រើនជាងនេះ
- ជនពិការ
- គ្រួសារចំណូលទាបដល់មធ្យម ដែលមានកូនក្នុងបន្ទុកអាយុ 18 ឆ្នាំ និងតិចជាងនេះ
- យុវជន ដែលរួចផុតពីអាណាព្យាបាល អាយុ 18-24 ឆ្នាំ
- អតីតយុទ្ធជន
- ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ឬបទឧក្រិដ្ឋហិង្សាក្នុងរយៈពេល 6 ឆ្នាំ ឬ
- ស្ត្រីមានផ្ទៃពោះ ក្នុងត្រីមាសទីពីរ

ពុំតម្រូវឲ្យមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ទេ។

**របៀបស្នើសុំ៖**

ដើម្បីសាកសួរ **ហៅមកខ្សែទូរស័ព្ទត្រួតពិនិត្យជាមុនដោយស្វ័យប្រវត្តិ នៅលេខ 510-272-3700 (ភាសាអង់គ្លេស និងអេស្ប៉ាញ)**។ បើអ្នកបំពេញបាននូវលក្ខណៈវិនិច្ឆ័យជាគោលសម្រាប់ការពិចារណា បុគ្គលិកផ្នែកពិនិត្យ នឹងទាក់ទងមកអ្នក ដើម្បីធ្វើការត្រួតពិនិត្យបន្ថែម។ ជំនួយមិនត្រូវបានធានាទេ។

**សម្រាប់ព័ត៌មានបន្ថែម៖**

**វេបសាយ៖** https://alamedasocialservices.org/public/services/community/season_of_sharing.cfm

**សេវាការងារ**

## Welfare-to-Work (WTW)

សេវាដែល SSA ផ្តល់ឲ្យអ្នកទទួលជំនួយ CalWORKs បច្ចុប្បន្ន រួមមានការបណ្តុះបណ្តាល និងរកការងារឲ្យ ការសម្របក្នុងសង្គម ការគ្រប់គ្រងសំណុំរឿង អង់គ្លេសជាភាសាវិជ្ជាជីវៈទីពីរ និងសេវាគាំពារផ្សេងៗ ដូចជា ការថែទាំកុមារ ការដឹកជញ្ជូន និងចំណាយបណ្តុះបណ្តាល។

<u>សិទ្ធិទទួលបាន៖</u>

ត្រូវតែដាក់ពាក្យសុំ ឬកំពុងទទួលជំនួយ CalWORKs នាពេលបច្ចុប្បន្ន ដើម្បីចូលរួមក្នុង WTW។

**របៀបស្នើសុំ៖**

- **ទាក់ទងទីប្រឹក្សាការងារដែលគេចាត់តាំងឲ្យអ្នក** ដើម្បីសួរនាំអំពី WTW។
- ដើម្បីស្នើសុំជំនួយ CalWORKs **សូមមកការិយាល័យ SSA** ឬ **ចូលទៅវេបសាយ៖** www.mybenefitscalwin.org

## CalFresh Employment & Training Program

សេវាដែល SSA ផ្តល់ឲ្យអ្នកចូលរួម ដែលមានសិទ្ធិ ដើម្បីជួយពួកគេរកបានការងារធ្វើ រួមមាន៖

- តេស្តវាយតម្លៃ និងបទសម្ភាសន៍
- សិក្ខាសាលា Job Club ស្តីពីការរៀបចំប្រវត្តិរូបសង្ខេប និងពាក្យសុំការងារ ជំនាញសម្ភាសន៍ ដំបូន្មានស្តីពីការស្វែងរក និងការរក្សាការងារ។
- ជំនួយស្វែងរក និងព័ត៌មានពីការងារ
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរៀបចំ GED
- ឱកាសការងារនៅអង្គការមិនរកប្រាក់ចំណេញ សម្រាប់អ្នកចូលរួម ដើម្បីទទួលបានបទពិសោធន៍ការងារ

អ្នកចូលរួមក៏អាចទទួលបានសេវាគាំពារ និងជំនួយដឹកជញ្ជូន ចំណាយការងារ ឬបណ្តុះបណ្តាល ថ្លៃសិក្សា ថ្លៃប្រឡងតេស្ត សៀវភៅ និងសម្ភារសាលារៀន។

<u>សិទ្ធិទទួលបាន៖</u>

អ្នកត្រូវមានលទ្ធភាពធ្វើការ និងកំពុងទទួលឬស្នើសុំជំនួយទូទៅ/CalFresh ឬ Transitional CalFresh។ បើអ្នកកំពុងទទួលអត្ថប្រយោជន៍ CalFresh មិនមែនជាជំនួយ និងជាមនុស្សពេញវ័យមានកាយសម្បទារឹងមាំ គ្មានអ្នកក្នុងបន្ទុក នោះអ្នកក៏អាចចូលរួមក្នុងកម្មវិធីបានផងដែរ។ នេះមិនមែនជាកម្មវិធីត្រូវតែចូលរួមឡើយ។

**របៀបស្នើសុំ៖**

- **អ្នកទទួល CalFresh ឬ General Assistance** អាច**សាកសួរនៅការិយាល័យ SSA** ឬ**ទូរស័ព្ទមក 510-263-2420**។
- ដើម្បីស្នើសុំ CalFresh អានទំព័រទី 2។
- ដើម្បីស្នើសុំ General Assistance អានទំព័រទី 3។

## Individualized Career Services: Limited English Proficiency (LEP) Program

អ្នកទទួល Refugee Cash Assistance (RCA) ត្រូវបានគេតម្រូវឲ្យចូលរួមក្នុងសកម្មភាពការងារ និងបណ្តុះបណ្តាល។

ដៃគូសហគមន៍របស់ Social Services Agency ផ្តល់សេវាការងារ និងការបង្រៀនអង់គ្លេសជាភាសាវិជ្ជាជីវៈទីពីរ (ES/VESL) សម្រាប់អ្នកចូលរួម ដែលមិនសូវចេះអង់គ្លេស និងមិនចេះអង់គ្លេស។

គោលដៅ គឺដើម្បីមានការងារ និងឯករាជភាព។

អ្នកដែលអាចមានសិទ្ធិ៖

- ជនភៀសខ្លួន
- អ្នកសុំសិទ្ធិជ្រកកោន
- អតិថិជន CalWORKs
- អតិថិជន CalFresh
- អតិថិជនជំនួយទូទៅ

**របៀបសាកសួរ៖**

- បុគ្គល ដែលចង់ស្នើសុំ RCA ត្រូវតែដាក់ពាក្យសុំ CalWORKs **ដោយផ្ទាល់** នៅទីតាំងការិយាល័យ SSA ឬ**អនឡាញ** នៅ mybenefitscalwin.org

## Cal-Learn

Cal-Learn បម្រើក្មេងជំទង់មានផ្ទៃពោះ និងជាឪពុក/ម្តាយ ដែលកំពុងទទួលជំនួយសាច់ប្រាក់ តាមរយៈកម្មវិធី CalWORKs។ កម្មវិធីនេះបង្កើតឡើង ដើម្បីជួយក្មេងជំទង់ដែលជាឪពុក/ម្តាយ ឲ្យទទួលបានសញ្ញាបត្រវិទ្យាល័យ ឬ GED និងបោះជំហានដំបូងឆ្ពោះទៅសម្រេចគោលដៅអនាគតរបស់ខ្លួន។

សេវា រួមមានការគ្រប់គ្រងសំណុំរឿង ការថែទាំកុមារ និងការដឹកជញ្ជូនទៅសាលារៀន ធនធានអប់រំ និងការលើកទឹកចិត្តហិរញ្ញវត្ថុ ចំពោះលទ្ធផលសិក្សាល្អប្រសើរ និងការបញ្ចប់ការសិក្សា។

សិទ្ធិទទួលបាន៖

- ក្មេងជំទង់មានផ្ទៃពោះ ឬជាឪពុក/ម្តាយ អាយុក្រោម 19 ឆ្នាំ ដែលទទួលជំនួយ CalWORKs និង គ្មានសញ្ញាបត្រវិទ្យាល័យ ឬ GED ឬ
- អ្នកទទួលជំនួយ CalWORKs ជាមួយក្មេងជំទង់មានផ្ទៃពោះ ឬជាឪពុក/ម្តាយ ក្នុងសំណុំរឿង ដូចសេចក្តីបរិយាយខាងលើ។

**របៀបស្នើសុំ៖**

ត្រូវតែស្នើសុំ ឬបច្ចុប្បន្នកំពុងទទួលជំនួយ CalWORKs ដើម្បីចូលរួមក្នុង Cal- Learn។

**ដើម្បីស្នើសុំ CalWORKs៖**

- មកការិយាល័យ SSA ដោយផ្ទាល់។
- ចូលទៅ៖ www.mybenefitscalwin.org

**ដើម្បីសាកសួរពី Cal-Learn**

- ទាក់ទងទីប្រឹក្សាការងារជាកំណត់របស់អ្នក។

**សម្រាប់ព័ត៌មានបន្ថែម៖**
**គេហទំព័រ៖** www.alamedasocialservices.org/public/services/employment_and_training/cal_teen.cfm

## Youth Career Readiness Program: Summer and After School Youth Employment and Education Program (SASYEP)

យុវជនដែលចូលរួម អាចរកបាន $10 ក្នុងមួយម៉ោងពីការងាររដូវក្តៅ 20 ម៉ោងក្នុងមួយសប្តាហ៍ ជាមួយបទពិសោធន៍ការងាររយៈពេលច្រើនបំផុត 150 ម៉ោង។ ម្យ៉ាងទៀត អ្នកចូលរួមអាចរកបានប្រាក់រង្វាន់ហិរញ្ញវត្ថុ ពីការបំពេញសេចក្តីត្រូវការអប់រំរបស់ខ្លួន។ សេវាទាំងនេះត្រូវបានផ្តល់ជូនដោយ Alameda County Workforce Development Board។

**របៀបសាកសួរ៖**

ទាក់ទងអ្នកផ្តល់សេវាយុវជន៖ https://www.acwdb.org/youth.page

## Employment Development Department

Employment Development Department (EDD) រដ្ឋ Califonia ផ្តល់សេវាជាច្រើនទាក់ទងនឹងការងារ ក្នុងនោះរួមមាន៖

- សិក្ខាសាលាស្តីពីការស្វែងរកការងារ និងប្រវត្តិរូបសង្ខេប
- ព័ត៌មានការងារ ការឧទ្ទេសនាម និងការបណ្តុះបណ្តាល
- ការធានារ៉ាប់រងភាពគ្មានការងារ ជំនួយពិការភាពរបស់រដ្ឋ និងជំនួយសម្រាកដោយសារធុរៈគ្រួសារមានប្រាក់ឈ្នួល សម្រាប់កម្មករដែលមានលក្ខណៈសម្បត្តិ

**សម្រាប់ព័ត៌មានបន្ថែម៖**
**គេហទំព័រ៖** edd.ca.gov

## សេវាមនុស្សពេញវ័យ & ចាស់ជរា

### Adult Protective Services (APS)

APS ឆ្លើយតបនឹងការរាយការណ៍ពីបុគ្គល ពលរដ្ឋពាក់ព័ន្ធ សេវាសង្គមកិច្ច និងអ្នកផ្តល់សេវាថែទាំសុខភាព និងតំណាងស្ថាប័នអនុវត្តច្បាប់ អំពីមនុស្សពេញវ័យដែលពិការផ្នែកលូតលាស់ មនុស្សពេញវ័យពិការរូបកាយ និងផ្លូវចិត្ត និងចាស់ជរាដែលអាចរងការបំពាន ឬការកេងប្រវ័ញ្ចរូបកាយ ឬហិរញ្ញវត្ថុ។

<u>សិទ្ធិទទួលបាន៖</u>

ដោយមិនគិតពីចំណូល ជនណាដែលគេសង្ស័យថា រងការបំពាន ឬត្រូវគេទុកចោល ដែលមាន៖

- អាយុ 18 ដល់ 64 ឆ្នាំ ដែលពិបាករូបកាយ ឬផ្លូវចិត្តឬ
- អាយុ 65 ឆ្នាំ ឬច្រើនជាងនេះ។

**ដើម្បីរាយការណ៍ពីការបំពាន៖**

- **ទូរស័ព្ទ**លេខ 1-866-225-5277 ឬ1-866-CALL-APS

### Area Agency on Aging

បង្ការចាស់ជរា (អាយុ 60 ឬលើសនេះ) កុំឲ្យនៅតែឯង ត្រូវគេដាក់ក្នុងស្ថាប័នមុនកំណត់ កុំឲ្យមានការបំពាន និងលទ្ធផលសុខភាពអវិជ្ជមាន។

សេវារួមមាន៖ ការថែទាំមនុស្សពេញវ័យពេលថ្ងៃ ការគ្រប់គ្រងសំណុំរឿង សេវាសហគមន៍ ការបង្ការជំងឺ ការបង្ការការបំពានលើចាស់ជរា ការឧបត្ថម្ភអ្នកថែទាំក្នុងគ្រួសារ ការលើកកម្ពស់សុខភាព សេវាធានារ៉ាប់រង ប្រឹក្សា និងនិយាយគាំទ្រសុខភាព (HICAP) ព័ត៌មាន & ជំនួយ សេវាផ្លូវច្បាប់ កម្មវិធីអាហារបំប៉ន កម្មវិធី Ombudsman ការងារចាស់ជរា និងការបង្ការរបួសលើចាស់ជរា

**របៀបសាកសួរ៖**

- **ទូរស័ព្ទមកផ្នែកព័ត៌មាន និងជំនួយចាស់ជរា** លេខ1-800-510-2020 or 510-577-3530។

**សេវាគាំពារនៅផ្ទះ (In-Home Supportive Services)**

កម្មវិធី IHSS ផ្តល់ជំនួយដល់ចាស់ជរា ជនពិការភ្នែក និងជនពិការ ដែលមានសិទ្ធិ ដើម្បីឲ្យពួកគេអាចបន្តរស់នៅដោយសុវត្ថិភាពក្នុងផ្ទះរបស់ខ្លួន។ កម្មវិធី IHSS ផ្តល់សេវា ផ្អែកតាមសមត្ថភាពរបស់អតិថិជនក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ ហើយអាចរួមមាន ការបញ្ចុក ការងូតទឹក ការស្លៀកពាក់ ការសម្អាតផ្ទះ ការបោកគក់ ការដើរផ្សារ និងការរៀបចំអាហារ និងលាងសម្អាត ផ្លូវដង្ហើម ការថែទាំពោះវៀន និងប្លោកនោម ការឡើង និងងើបចេញពីគ្រែ ការអមដំណើរទៅតាមការណាត់ជួបវេជ្ជសាស្ត្រ សេវាវេជ្ជសាស្ត្រក្រោមការត្រួតពិនិត្យរបស់វេជ្ជបណ្ឌិត និងការត្រួតពិនិត្យការពារ។

<u>សិទ្ធិទទួលបាន៖</u>

មិនអាចរស់នៅក្នុងផ្ទះដោយសុវត្ថិភាព បើគ្មានជំនួយទេហើយ៖

- កំពុងទទួលអត្ថប្រយោជន៍ Medi-Cal
- ពិការភ្នែក
- ពិការ ឬ
- អាយុ 65 ឆ្នាំ ឬលើសនេះ

**របៀបស្នើសុំ៖**

- **ហៅមកលេខទូរស័ព្ទ** 510-577-1900
- **ដោយផ្ទាល់** នៅ IHSS Lobby ពីថ្ងៃចន្ទ ដល់សុក្រ ម៉ោង 8:30 am - 5:00 pm នៅ Eastmont Town Center<br>6955 Foothill Boulevard<br>1st floor - Suite 143<br>Oakland, CA 94605

## សេវាកុមារ និងគ្រួសារ

**ផ្នែកស៊ើបអង្កេតលើការបំពាន & ការធ្វេសប្រហែស**

**ខ្សែទូរស័ព្ទបន្ទាន់ស្តីពីការបំពានលើកុមារ និងការឆ្លើយតបក្នុងគ្រាអាសន្ន សម្រាប់សេវាការពារកុមារ៖**

**ខ្សែទូរស័ព្ទបន្ទាន់ 24 ម៉ោង៖ 510-259-1800**

ខ្សែទូរស័ព្ទបន្ទាន់ ឆ្លើយតបនឹងអង្គភាពអនុវត្តច្បាប់ មន្ទីរពេទ្យ អ្នករាយការណ៍តាមច្បាប់ និងសាធារណជន ដែលហៅទូរស័ព្ទដើម្បីរាយការណ៍ពីការបំពានលើកុមារ ឬទទួលបានព័ត៌មាន។ ខ្សែទូរស័ព្ទបន្ទាន់ ក៏ផ្តល់ការប្រឹក្សាយោបល់អំពីលទ្ធភាពបង្វែរបញ្ជូនទៅ និងផ្តល់ព័ត៌មានពីសេវាសហគមន៍ផងដែរ។

ក្នុងអំឡុងម៉ោងធ្វើការ (7:30 am - 5:30 pm ក្នុងថ្ងៃធ្វើការ) ការបង្វែរបញ្ជូន និងការរាយការណ៍ តាមខ្សែទូរស័ព្ទបន្ទាន់ ស្តីពីកុមារ ដែលគេថា ស្ថិតក្នុងគ្រោះថ្នាក់ដោយសារការបំពាន ការទុកចោល ឬការកេងប្រវ័ញ្ច គឺផ្នែកពិនិត្យការឆ្លើយតបក្នុងគ្រាអាសន្នជាអ្នកទទួល។

ក្រោយម៉ោងធ្វើការ (7:00 pm - 7:00 am) និងនៅថ្ងៃចុងសប្តាហ៍/ថ្ងៃសម្រាក ផ្នែក Eden Information and Referral (Eden I&R) ជាអ្នកទទួលទូរស័ព្ទ ហើយត្រូវបង្វែរបញ្ជូនទៅបុគ្គលិកក្រោយម៉ោងធ្វើការ។

## ការបង្រួបបង្រួម & ការទ្រទ្រង់គ្រួសារ

**ការបង្រួបបង្រួមគ្រួសារ (Family Reunification (FR))** មានគោលដៅ ដើម្បីបង្រួបបង្រួមកុមារជាមួយឪពុក/ម្ដាយ ក្នុងផ្ទះដែលមានសុវត្ថិភាព ស្ថេរភាព និងគាំពារ។ ករណី FR ទាំងអស់ ពាក់ព័ន្ធនឹងកុមារ ដែលត្រូវដកពីការថែទាំ និងការគ្រប់គ្រង។ សេវាបង្រួបបង្រួមគ្រួសារ ត្រូវផ្ដល់ជូនសម្រាប់រយៈពេល ដែលកំណត់ដោយច្បាប់រដ្ឋ និងរដ្ឋសហព័ន្ធ។

**ការទ្រទ្រង់គ្រួសារ (Family Maintenance (FM))** ធ្វើការជាមួយនឹងគ្រួសារ ដែលមានកូនត្រូវបានកំណត់ក្នុងបន្ទុកតុលាការ ដោយសារការបំពានឬការទុកចោល ប៉ុន្តែដែលបន្តស្នាក់នៅក្នុងផ្ទះ ផ្អែកតាមការវាយតម្លៃលើសុវត្ថិភាព ខណៈដែលកំពុងផ្ដល់សេវា។ គោលដៅ គឺដើម្បីទ្រទ្រង់ និងពង្រឹងគ្រួសារ ពេលណាដែលអាចធ្វើទៅបាន។

**ការទ្រទ្រង់គ្រួសារក្រៅផ្លូវការ** គឺជាកិច្ចអន្តរាគមន៍ក្រៅផ្លូវតុលាការ សម្រាប់គ្រួសារ ដែលចង់ចូលរួមនៅក្នុងសេវាស្ម័គ្រចិត្ត និងកម្មវិធីនៃការគ្រប់គ្រងសំណុំរឿងក្រៅផ្លូវការ។

**សម្រាប់ព័ត៌មានបន្ថែម៖**
https://alamedasocialservices.org/public/services/children_and_family/index.cfm

## សេវាអាណាព្យាបាល

បុគ្គលជាសាច់ញាតិ និងមិនមែនជាសាច់ញាតិ អាចក្លាយជាអាណាព្យាបាលរបស់កូនចិញ្ចឹម។ ផ្នែកអាណាព្យាបាលផ្លូវច្បាប់របស់ Social Services Agency ធ្វើការជាមួយអាណាព្យាបាល ដែលកំពុងស្នាក់នៅក្នុងខោនធីAlameda ដែលមិនមែនជាសាច់ញាតិ ដែលកំពុងទទួលជំនួយឧបត្ថម្ភធនសម្រាប់ការថែទាំចិញ្ចឹម។ បុគ្គលិក Child Welfare បន្តទាក់ទងអាណាព្យាបាល និងយុវជន ដោយជួបប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំ (រៀងរាល់ 6 ខែ) ដោយផ្ដល់សេវាគ្រប់គ្រងសំណុំរឿង ដែលសង្កត់ធ្ងន់លើការបញ្ជូនបង្វែរ និងកិច្ចអន្តរាគមន៍។

**សម្រាប់ព័ត៌មានបន្ថែម៖**
https://alamedasocialservices.org/public/services/children_and_family/faq.cfm

## សេវាថែទាំចិញ្ចឹម

**សេវារកកន្លែង** ផ្ដល់សេវាដែលឆ្លើយតប និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដល់កុមារ ដែលចង់រកកន្លែងផ្សេងក្រៅពីផ្ទះ។ ការដាក់ឲ្យនៅក្នុងផ្ទះរបស់សាច់ញាតិដែលចង់ទទួល គឺជាជម្រើសទីមួយសម្រាប់កុមារគ្រប់រូប។

**សិទ្ធិទទួលបានការថែទាំចិញ្ចឹម** កំណត់ពីសិទ្ធិដំបូង និងសិទ្ធិបន្តរបស់កុមារ ក្នុងការទទួលបានការថែទាំក្រៅផ្ទះ សម្រាប់កម្មវិធី Medi-Cal និងជំនួយហិរញ្ញវត្ថុ ដូចជា កម្មវិធីជំនួយគ្រួសារមានកូនក្នុងបន្ទុក - ការថែទាំចិញ្ចឹម (Aid to Families with Dependent Children – Foster Care (AFDC-FC))។ ប្រាក់ AFDC-FC ត្រូវបង់ទៅឲ្យអ្នកថែទាំ សម្រាប់ការថែទាំ និងឧបត្ថម្ភកូនចិញ្ចឹម ដែលត្រូវបានកំណត់ឲ្យរស់នៅក្នុងផ្ទះរបស់គេ។

**ខ្សែទូរស័ព្ទព័ត៌មានស្ដីពីការថែទាំចិញ្ចឹម៖**

510-268-2500

អ្នកថែទាំ និងអ្នកផ្ដល់សេវាបច្ចុប្បន្នអាចទូរស័ព្ទ សួរសំណួរពាក់ព័ន្ធនឹងសិទ្ធិទទួល ដែលទាក់ទងនឹងកូនចិញ្ចឹម។

## ការសុំកូន

Social Services Agency នៃខោនធី Alameda ទទួលបានអាជ្ញាប័ណ្ណជាទីភ្នាក់ងារសុំកូនសាធារណៈដែលចេញដោយក្រសួងសេវាសង្គមកិច្ចនៃរដ្ឋ California។ កម្មវិធីសុំកូនផ្ដល់ជូនសេវាទាក់ទងនឹងការសុំកូនក្នុងបន្ទុកតុលាការ ក្នុងប្រព័ន្ធសង្គមកិច្ចកុមារ ជានីតិវិធីហៅថា ការសុំកូនតាមទីភ្នាក់ងារ។

កម្មវិធីសុំកូន ក៏ផ្ដល់ជូននូវសេវាសុំកូនដោយឯករាជ្យ និងដោយឪពុក/ម្ដាយចុង សម្រាប់កូនមិនស្ថិតក្នុងបន្ទុកផងដែរ។

**សម្រាប់ព័ត៌មានបន្ថែម៖**

**ព័ត៌មានទូទៅពីការសុំកូន៖**

510-268-2422

**ព័ត៌មានពីការសុំកូន ឪពុក/ម្ដាយចិញ្ចឹម អាជ្ញាប័ណ្ណចិញ្ចឹម៖** 510-259-3575

**ការសុំកូនដោយឯករាជ្យ៖** 510-268-2428

**ការសុំកូនដោយឪពុក/ម្ដាយចុង៖** 510-268-4276

## — សេវាកុមារ និងគ្រួសារ ត —

**សេវាគាំពារសាច់ញាតិ (Kinship Support Services (KSSP)**

សេវាគាំពារគ្រួសារក្នុងសហគមន៍សម្រាប់អ្នកថែទាំដែលជាសាច់ញាតិ និងកុមារ ក្នុងផ្ទះរបស់ពួកគេ រួមមាន៖

**Family Support Services of the Bay Area**
ទូរស័ព្ទ៖ 510-834-2443
401 Grand Ave #500, Oakland, CA 94610

**Lincoln Child Center**
ទូរស័ព្ទ៖ 510-583-8026
1149 A Street, Hayward, CA 9454

## សេវារៀបចំបង់ពន្ធ គ្មានចំណាយសេវា

**កម្មវិធីជំនួយស្ម័គ្រចិត្តរៀបចំបង់ពន្ធប្រាក់ចំណូល (Volunteer Income Tax Assistance (VITA) Program)**

សេវារៀបចំបង់ពន្ធគ្មានចំណាយសេវា មានជូនអតិថិជន Social Service Agency និងបុគ្គល និងគ្រួសារមានចំណូលទាប ក្នុងខោនធី Alameda ទាំងមូល។ អ្នករៀបចំបង់ពន្ធស្ម័គ្រចិត្ត ដែលមានលិខិតបញ្ជាក់ពី IRS របស់យើង ជួយធានាថា អ្នកជាប់ពន្ធចំណូលទាប ទទួលបានក្រេឌីត និងការកាត់ប្រាក់ពន្ធទាំងអស់ ដែលពួកគេទទួលបាន។

កម្មវិធី VITA ដំណើរការជាប្រចាំឆ្នាំ ចាប់ពីចុងខែមករា ដល់ពាក់កណ្ដាលខែមេសា។

**របៀបស្នើសុំ៖**
**ត្រូវធ្វើការណាត់ជួប** នៅកន្លែងរៀបចំបង់ពន្ធរបស់ SSA។ ចូលក្នុងប្រព័ន្ធអនឡាញ ដើម្បីកំណត់កាលវិភាគណាត់ជួប៖ https://alamedasocialservices.org/eitc.cfm

**សម្រាប់ព័ត៌មានបន្ថែម៖**

- **ទូរស័ព្ទមកលេខ** 510-271-9141
- **ផ្ញើអ៊ីម៉ែលមក** vita.eitc@acgov.org
- **គេហទំព័រ៖** www.alamedasocialservices.org/public/services/community/eitc/free_tax_services.cfm

## ធនធានសហគមន៍

អង្គការសម្ព័ន្ធជនជាតិអាហ្វហ្គានី
Afghan Coalition
510-745-1680
www.afghancoalition.org

អង្គការដៃគូអប់រំ និងច្បាប់សម្រាប់ជនអន្តោប្រវេសន៍នៅខោនធី Alameda
Alameda County Immigrant Legal and Education Partnership
510-241-4011

អង្គការចុះផ្សព្វផ្សាយច្បាប់សម្រាប់អ្នកកោះអាស៊ីប៉ាស៊ីហ្វិក
Asian Pacific Islander Legal Outreach
510-251-2846
www.apilegaloutreach.org

អង្គការជំនួយផ្លូវច្បាប់នៅ Bay Area
Bay Area Legal Aid
800-551-5554
https://baylegal.org

អង្គការមនុស្សធម៌កាតូលិកនៅ East Bay
Catholic Charities of the East Bay
510-768-3100
www.cceb.org

មជ្ឈមណ្ឌល
Centro Legal de la Raza
510-437-1554
https://centrolegal.org

មជ្ឈមណ្ឌលច្បាប់សហគមន៍ East Bay
East Bay Community Law Center
510-548-4040
https://ebclc.org

វិទ្យាស្ថានអន្តរជាតិ East Bay
International Institute of the East Bay
510-451-2846
https://iibayarea.org